រួមគ្នាស្រឡាញ់នឹងថែរក្សាវប្បធម៌ខ្មែរ!

# ២២ - រឿង អណ្ដើក និងស្វា





**Marseillan Plage -**

Personen: 4 max, 1 Schlafzimmer

**Reservieren**

fewo-direkt.de

មានរឿងនិទានមួយថា អណ្ដើក និងស្វា វាសុំធ្វើដន្លងគ្នា តែគ្មានកូនចៅទៅចងពន្ធអ្វីទេ គ្រាន់តែនិយាយថា សុំគ្នាធ្វើដន្លង ។ សត្វទាំងពីរ ស្រឡាញ់រាប់អានគ្នា ដូចដន្លងអ្នកទាំងពួងនោះដែរ ។ លុះចំណេរយូរទៅ ដន្លងខាងស្វានោះគេមានកូនត្រូវរៀបការ គេហៅភ្ញៀវពួកស្វា សន្មតថ្ងៃនឹងស៊ីការ ទើបនឹកឃើញអណ្ដើកជាដន្លងថា « យើងការកូននេះហៅភ្ញៀវអស់ហើយ នៅតែអណ្ដើកជាដន្លង មិនទាន់បានទៅប្រាប់ឥឡូវ ជិតថ្ងៃការណាស់ទៅហើយ បើដូច្នោះឲ្យបម្រើទៅអញ្ជើញគាត់ផង បំណាច់យើងរាប់អានគ្នា យូរឆ្នាំណាស់មកហើយ » គិតហើយក៏ចាត់បម្រើឲ្យទៅអញ្ជើញ ។ ថ្ងៃដែលគេប្រជុំញាតិស៊ីការនោះ អណ្ដើកក៏ទៅដល់ដែរ តែនឹងឡើងទៅស៊ីផឹកនឹងគេមិនរួច ។ ពួកស្វាបានឃើញ ក៏ទៅប្រាប់ដន្លងស្វាថា « ត្បិតដន្លងអណ្ដើកមកដល់ហើយ នៅឯក្រោមដើមឈើ » ។ ដន្លងស្វាចុះមក ឃើញអណ្ដើកក៏ប្រាប់ថាដន្លងឯងឡើងមិនរួចនឹងគេ មានតែដន្លងឯងខាំវល្លិនេះចុះ យើងនឹងស្រាវឡើង ប៉ុន្តែបើមិនទាន់ដល់ទៅកន្លែងដែលយើងអង្គុយទេ ដន្លងឯងកុំនិយាយឲ្យសោះ ទោះបីឃើញអ្វី ឬគេថាអ្វីក៏ដោយ, តែនិយាយធ្លាក់មកស្លាប់ហើយ ។ អណ្ដើកទទួលបណ្ដាំដន្លងនោះសព្វគ្រប់ហើយ ក៏ទទួលខាំវល្លិ ។ ពួកស្វាទាំងប៉ុន្មាន ក៏ស្រាវវល្លិនោះឡើង នាំអណ្ដើកទៅឯថ្នាក់លើ ។ លុះទៅជិតដល់កន្លែង ដែលគេនឹងដាក់នោះ ជួនជាដន្លងស្រីស្វា ឃើញអណ្ដើក ក៏សួរដោយរាប់អានថា « ដន្លង ! សុខសប្បាយទេឬ ? » ។ អណ្ដើកភ្លេចពាក្យបណ្ដាំ ហាមាត់ស្ដីទៅនឹងដន្លង ក៏របូតមាត់ ធ្លាក់ខ្លួនដល់ដីបែកស្នូកដូចគេបោកនឹងថ្ម ស្លាប់នៅវេលានោះ ខានស៊ីការនោះទៅ ។

> ***មាត់អណ្ដើក***

ខ្លះថា អណ្ដើក និងកំប្រុក ។ កម្ពុជសុរិយា លេខ ៧ – ៨ – ៩ ឆ្នាំ ១៩៣៣ – ៤ ទំព័រ ១៥២ មិនឃើញមានឈ្មោះអ្នករៀបរៀងទេ ។

+1 +1 Recommend this on Google

ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអ៊ីមែលក្នុងប្រអប់នេះ

Email address... ចង់បាន

នាំមកជូនលោកអ្នកដោយ

